ព្រះរាជាណាចក្រកម្ពុជា

សាលាឧទ្ធរណ៍ភ្នំពេញ ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ១៤៣ / ១៦.០២.២០១២

***************

សាលដីកា

លេខ: ៧៦ ក្រ.III.ស/១០.១០.២០១២

តាងនាមប្រជារាស្ត្រខ្មែរ

សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញាឆ្នាំ២០១២ ដោយមានសមាសភាពដូចតទៅ:

__ក្រុមប្រឹក្សាជំនុំជម្រះ__

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោកស្រី [redacted] ជាចៅក្រមប្រឹក្សា

__តំណាងមហាអយ្យការ__

លោក [redacted]

__ក្រឡាបញ្ជី__

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៤៣ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ រវាង ៖

១. ជនជាប់ចោទឈ្មោះ [redacted] សុខុម ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរៈនៅផ្ទះ ទីលំនៅកំណើត សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទីលំនៅមុ[redacted] ផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted] (រ) នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ៨ខែ ពីបទជក់ (គ្រឿងញៀន)។

__ជាប់ចោទពីបទ:__ ជួញដូរគ្រឿងញៀនខុសច្បាប់ប្រព្រឹត្តនៅ ផ្ទះលេខ២៧AE$_0$ ផ្លូវលេខ៣១៦ហ្សិត ក្រុម៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ថ្មី នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

__ដំណើររឿងមានដូចតទៅ ៖__

កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ វេលាម៉ោង ១៣ និង៣០នាទី កម្លាំងនគរបាលប៉ុស្តិ៍ផ្សារដើមគរ និងនគរបាលខណ្ឌទួលគោក ដោយមានការចូលរួមពីលោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូង ⁄.

រាជធានីភ្នំពេញ បានចុះបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀន និងប្រើប្រាស់គ្រឿងញៀនមួយកន្លែង នៅចំណុចផ្ទះលេខ២៧AE₀ ផ្លូវលេខ៣១៦ហ្សិត ក្រុម៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក្រោយមកក៏ឃាត់ខ្លួនបានមនុស្សចំនួន៥នាក់ មានឈ្មោះ [redacted] ម៉ឹងឆាយ ជាអ្នកជួញដូរគ្រឿងញៀន និងផ្ដល់ទីតាំងសម្រាប់ប្រើប្រាស់គ្រឿងញៀន និងឈ្មោះ [redacted] សុខរង្សី, [redacted] រចនា, [redacted] បញ្ញា, [redacted] ចន្ទ័ឧត្ដម ជាអ្នកប្រើប្រាស់គ្រឿងញៀន ហើយបានដកហូតវត្ថុតាងរួមមានៈ ថ្នាំញៀនប្រភេទក្រាមពណ៌សថ្លា (ទឹកកក) ចំនួន១១កញ្ចប់ ដែលមានទម្ងន់សរុប ១,៦៧ក្រាម និងថ្នាំម្សៅពណ៌ក្រហម ១កញ្ចប់តូច ដែលមានទម្ងន់សរុប ០,០៤ក្រាម ព្រមទាំងសំភារៈសម្រាប់ប្រើប្រាស់គ្រឿងញៀនមួយចំនួន។ ក្រោយពីធ្វើការសាកសួរក៏បានបន្តឃាត់ខ្លួនជនសង្ស័យចំនួន៣នាក់ទៀត ឈ្មោះ [redacted] ឌីណា, [redacted] សុវណ្ណារ៉ា និងឈ្មោះ [redacted] សុខុម ជាអ្នកជួញដូរគ្រឿងញៀន ព្រមទាំងដកហូតបានវត្ថុតាងរួមមាន ថ្នាំញៀនប្រភេទក្រាមពណ៌សថ្លា (ទឹកកក) ចំនួន៤កញ្ចប់។ ចំណែកឈ្មោះ ញ៉េប, ឈ្មោះ សិទ្ធ, ឈ្មោះ សាន្ត និងឈ្មោះ តូ បានរត់គេចខ្លួនបាត់។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១៥៨ កប៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១- ផ្ដន្ទាទោសៈ

ក- ឈ្មោះ [redacted] ម៉ឹងឆាយ ហៅ ទិត្យ ភេទប្រុស អាយុ២៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៣ឆ្នាំ (បីឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៦.០០០.០០០៛ (ប្រាំមួយលានរៀល) ពីបទ សម្រួលដោយចេតនាឲ្យប្រើប្រាស់គ្រឿងញៀន និង ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះលេខ២៧AE₀ ផ្លូវលេខ៣១៦ហ្សិត ក្រុម៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥.២ថ្មី និងមាត្រា ៣៣ថ្មី កថាខណ្ឌទី១ នៃច្បាប់វិសោធនកម្ម ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ- ឈ្មោះ [redacted] សុខុម ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៤ឆ្នាំ (បួនឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៨.០០០.០០០៛ (ប្រាំបីលានរៀល)។

គ- ឈ្មោះ [redacted] ឌីណា ហៅ ស ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២ឆ្នាំ ៦ខែ (ពីរឆ្នាំ និងប្រាំមួយខែ) និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០៛ (បួនលានរៀល)។

ឃ- ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ២ឆ្នាំ (ពីរឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០៛ (បួនលានរៀល)។

ពីបទ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅចំណុចផ្ទះលេខ២៧AE₀ ផ្លូវលេខ៣១៦ហ្សិត ក្រុម៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៣ ថ្មី កថាខណ្ឌទី១ នៃច្បាប់វិសោធនកម្ម ច្បាប់

ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២- វត្ថុតាងដូចក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ៣៩១ វ.ត ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ រួមមាន:

ក- ស្រោមសំបុត្រពណ៌សចំនួន០៣ ដាក់គ្រឿងញៀនបិទជិត ដែលក្រាមពណ៌សថ្លា (ទឹកកក) មានទម្ងន់សរុប ៤,២៦ក្រាម និងម្សៅពណ៌ផ្កាឈូកទម្ងន់ ០,០៣ក្រាម, ក្នុងនោះស្រោមសំបុត្រទី១ មានក្រាមសថ្លា (ទឹកកក) ទម្ងន់ ២,២២ក្រាម ស្រោមសំបុត្រទី២ មានក្រាមសថ្លា (ទឹកកក) ទម្ងន់ ១,៦០ក្រាម និងម្សៅពណ៌ផ្កាឈូកទម្ងន់ ០,០៣ក្រាម និងស្រោមសំបុត្រទី៣ មានក្រាមសថ្លា (ទឹកកក) ទម្ងន់ ០,៤៤ក្រាម ត្រូវរឹបអូសបំផ្លាញចោល។

ខ- ម៉ូតូមួយគ្រឿង ម៉ាកហុងដាសេ១២៥ ស៊េរីឆ្នាំ២០១១ ពាក់ស្លាកលេខភ្នំពេញ ១AV ២៤៦០ លេខតួ និងលេខម៉ាស៊ីន ៨៥៥៧៣៦៥ គ្មានកញ្ចក់ ទូរស័ព្ទចំនួន០៥គ្រឿង ម៉ាកណូគាចំនួន០៤គ្រឿង របស់ចិនមួយគ្រឿង និងម៉ាកសូនីអេរិកសាន់មួយគ្រឿង និងលុយខ្មែរចំនួន ២០៦.២០០រ(ម្ភៃម៉ឺនប្រាំមួយពាន់ពីររយ-រៀល) និងលុយដុល្លាចំនួន ៤៩$ (សែសិបប្រាំបួនដុល្លាអាមេរិក) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]ុងឆាយ, ឈ្មោះ [redacted] ឌីណា, ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណារ៉ា មេធាវីការពារជនជាប់ចោទលោក [redacted] សុផល និងលោក [redacted] ហៃ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុខុម ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១១៨ កប៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] សុខុម ឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍នឹងសាលក្រម មិនសុខចិត្ត ព្រោះពេលសមត្ថកិច្ចចាប់ខ្លួន ខ្លួនអត់មានវត្ថុតាងនៅជាប់ខ្លួនទេ ខ្លួនអត់បានប្រព្រឹត្តទេ ខ្លួនអត់បានជួញដូរគ្រឿងញៀនទេ ខ្លួនត្រូវចាប់ខ្លួនដោយអត់ដឹងរឿងអ្វីទាំងអស់,

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា ឆ្លើយនៅសាលាដំបូងរាជធានីភ្នំពេញ។

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] សុខុម បានឆ្លើយនៅនគរបាល។

ជនជាប់ចោទឈ្មោះ [redacted] សុខុម ឆ្លើយថា ខ្លួនសុំទទួលស្គាល់ចម្លើយនេះ ខ្លួនពិតជាបានប្រព្រឹត្តមែន សំណូមពរ សុំតុលាការបន្ធូរបន្ថយទោសឲ្យខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់របាយការណ៍រឿង ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលនេះ ឃើញថា ជនជាប់ចោទដែលជាបក្សពួក [redacted] សុខុម ត្រូវបានសមត្ថកិច្ចចាប់ខ្លួន ជាក់ស្តែងចាប់បានថ្នាំញៀន និងឈាន ទៅដល់ការចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] សុខុម ហើយជនជាប់ចោទរូបនេះបានទទួលសារភាពនៅ នគរបាល ស៊ីសង្វាក់ទៅនឹងចម្លើយរបស់បក្សពួកខ្លួនដែលសមត្ថកិច្ចចាប់ខ្លួនបានជាក់ស្តែងនោះ។ ជនជាប់ចោទធ្លាប់បានប្រព្រឹត្ត អំពើជួញដូរគ្រឿងញៀននេះ មានសាលក្រមផ្តន្ទាទោសជាប់គុក៨ខែម្តងហើយ ហើយ ប្រព្រឹត្តបទដដែលទៀត, នេះជាករណីមិនរាងចាល ត្រូវបានសាលាដំបូងផ្តន្ទាទោស៤ឆ្នាំលើសពីជនជាប់ចោទ ដទៃទៀត ដែលម្នាក់ៗ ត្រឹមតែ២ឆ្នាំ ឃើញថា សមល្មមតាមច្បាប់ហើយ យោងតាមមាត្រា៨៨ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៣៣ ថ្មី កថាខណ្ឌទី១ នៃច្បាប់វិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដូចបទចោទរបស់អយ្យការអមសាលាដំបូង, តែតាមការសន្និដ្ឋានទោសរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារង សុំក្រុមប្រឹក្សាបន្ថយទោសលើជនជាប់ចោទរូបនេះ ឲ្យស្មើនឹងជនជាប់ចោទដទៃទៀត គឺមានកំរិតទណ្ឌកម្មត្រឹម ២ឆ្នាំ វិញនោះ តំណាងមហាអយ្យការសូមជូនក្រុមប្រឹក្សាពិចារណា។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ និងអំណានចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] សុខុម ជាជនជាប់ចោទ ធ្វើនៅក្នុង កំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ សមត្ថកិច្ចបានចុះបង្ក្រាបបទល្មើសជួញដូរគ្រឿងញៀន និង ប្រើប្រាស់គ្រឿងញៀន នៅចំណុចផ្ទះលេខ២៧អាអឺ០ ផ្លូវលេខ៣១៦ហ្សិត ក្រុម៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ចាប់បានជនល្មើសមួយចំនួន, ក្រោយការសាកសួរ ទើបឈានទៅចាប់ជនជាប់ចោទឈ្មោះ [redacted] ឌីណា [redacted] សុវណ្ណារ៉ា និង [redacted] សុខុម ជាក្រោយ។

- នៅសវនាការ នាសាលាឧទ្ធរណ៍ ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានជួញដូរគ្រឿង ញៀនមែន តែនៅពេលចាប់ខ្លួន គ្មានភស្តុតាងអ្វីនៅជាប់នឹងខ្លួនទេ, ចម្លើយជនជាប់ចោទថា ខ្លួនធ្លាប់ជាប់ ពន្ធនាគារ៨ខែ តែគ្មានឃើញសាលក្រមភ្ជាប់បញ្ជាក់។

៣. មានពិរុទ្ធលើជនជាប់ចោទពីបទ ជួញដូរគ្រឿងញៀន ប្រព្រឹត្តនៅចំណុច ផ្ទះលេខ២៧អាអឺ០ ផ្លូវលេខ៣១៦ហ្សិត ក្រុម៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១១ បទល្មើសមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣៣ ថ្មី កថាខណ្ឌ១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤. សាលក្រមព្រហ្មទណ្ឌលេខ ១១៨ កប៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចត្រឹមត្រូវ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី១«ខ» ស្តីពីទណ្ឌកម្មដាក់ពន្ធនាគារ គួរកែប្រែឲ្យបានសមស្រប តាមសកម្មភាពល្មើស ក្រៅពីនេះ គួរទុកនៅដដែល។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៥ខែធ្នូឆ្នាំ២០១១របស់ឈ្មោះ [redacted] សុខុម ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៨កប៥ ចុះថ្ងៃទី២៩ ខែវិច្ឆិកាឆ្នាំ២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្មដាក់ពន្ធនាគារ ត្រូវកែប្រែមកជា០២ (ពីរ) ឆ្នាំ វិញ, ក្រៅពីនេះទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ, បើកផ្លូវតវ៉ាតាមច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.................................................................................................................................

បានឃើញ
ប្រធានសាលាឧទ្ធរណ៍

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ, ថ្ងៃទី 04 ខែ 6 ឆ្នាំ ២០១៤
ក្រឡាបញ្ជី